# ប្រទេសកម្ពុជាមានការតាំងចិត្តដើម្បីការពារសិទ្ធិ និងអត្ថប្រយោជន៍ ពលករទេសន្តរប្រវេសន៍នៅក្នុងវិស័យនេសាទ និង កែច្នៃអាហារសមុទ្រ

ដោយទទួលបានការគាំទ្រថវិកាពីសហភាពអឺរ៉ុប អង្គការអន្តរជាតិខាងការងារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកដំណើរការគម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ជាមួយស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា និងឯកភាពតាមផែនការសកម្មភាព។

**ព័ត៌មាន ភ្នំពេញ ២ កញ្ញា ២០២១**



©ILO

កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដំបូងរបស់ខ្លួននាថ្ងៃទី២ ខែកញ្ញា ឆ្នាំ ២០២១ នៅភ្នំពេញ ប្រទេសកម្ពុជា។

ភាគីពាក់ព័ន្ធមកពីតំណាងរាជរដ្ឋាភិបាល និយោជក សហជីព និងអង្គការសង្គមស៊ីវិល បាន ពិភាក្សាអំពីគម្រោងកម្មវិធីថ្មី ហើយ បានបង្ហាញពីឆន្ទៈក្នុងការធ្វើការរួមគ្នាដើម្បីលើកម្ពស់ ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងស្របច្បាប់ ដើម្បីទទួល បានការងារសមរម្យក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រនៅប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍។

ក្នុងសន្ទរកថាស្វាគមន៍របស់ **លោក ប្រាយអាន ហូរណារី** ទីប្រឹក្សា និងជាប្រធានកិច្ចសហប្រតិបត្តិការ ប្រតិភូនៃសហភាពអឺរ៉ុប ប្រចាំនៅកម្ពុជា បានលើកឡើងថា "គម្រោងកម្មវិធីសិទ្ធិពលករនេសាទអាស៊ីអាគ្នេយ៍នេះ នឹងដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដែលពលករទេសន្តរប្រវេសន៍ទាំងបុរសនិងស្ត្រី បាននិងកំពុងជួបប្រទេះដែលត្រូវការការគាំពារកាន់តែខ្លាំងថែមទៀតក្នុងកំឡុង ពេលនៃការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍។ ដើម្បីធ្វើឱ្យប្រាកដថាមានការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព និងស្របច្បាប់គឺតម្រូវឱ្យមានការសម្របសម្រួលពីថ្នាក់តំបន់ ហេតុដូចនេះសហភាពអឺរ៉ុបនឹងបន្តលើក កម្ពស់ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ"។

**ឯកឧត្តម ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តម អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន បញ្ជាក់ថា "ក្រសួង សូមស្វាគមន៍ គម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ដែលនឹងចាប់ដំណើរការពីពេលនេះរហូត ដល់ឆ្នាំ២០២៤ ក្នុងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រក្នុងតំបន់អាស៊ីអា គ្នេយ៍ ក្រោមជំនួយបច្ចេកទេសនៃអង្គការអន្តរជាតិខាងការងារ (ILO), អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM), កម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP) និងជំនួយខាងហិរញ្ញវត្ថុពីសហភាពអឺរ៉ុប (EU)។ ដើម្បីអាចឈានទៅដំណើរការគម្រោងថ្មីនៃកម្មវិធីសិទ្ធិ ពលករនេសាទនៅអាស៊ីអាគ្នេយ៍នេះ ក៏ដូចជាការការពារនិងលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាក្នុងវិស័យ នេសាទឱ្យបានកាន់តែល្អប្រសើរ និងប្រកបដោយជោគជ័យ សិក្ខាសាលាពិគ្រោះយោបល់នេះ មានភារកិច្ចៈ ១). សិក្សាពិនិត្យ មើលឡើងវិញអំពីសិទ្ធិរបស់ពលករនេសាទ ក៏ដូចជាតួនាទីរបស់ភាគីពាក់ព័ន្ធនានានៅ កម្ពុជាក្នុងការការពារ និងលើកកម្ពស់សិទ្ធិ ពលករក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ ដែលសព្វថ្ងៃមានកាន់តែច្រើននៅបរទេស ជាពិសេសនៅប្រទេសថៃ ២). ស្វែង យល់រកឱ្យឃើញសកម្មភាពនានាជាអាទិភាពសម្រាប់អន្តរាគមន៍រយៈពេលមធ្យមនិងរយៈពេលវែង ដែលស្ថិតក្នុងកិច្ចការពារ និង លើកកម្ពស់សិទ្ធិពលករទាំងនេះ ដោយត្រូវកំណត់យកអនុសាសន៍ល្អៗ និងកំណត់អំពីអង្គភាពនាំមុខ និងអង្គភាពត្រូវសហការ និង ៣). រៀបចំ និងបង្កើតគណៈកម្មការប្រឹក្សាកម្មវិធីថ្នាក់ជាតិមួយ ដែលមានសមាសភាពគ្រប់គ្រាន់ និងមានសម្ថភាពពេញលេញ សម្រាប់ដឹកនាំនិងតម្រង់ទិសការងារ នៃកម្មវិធីថ្មីមួយនេះឱ្យទទួលបានជោគជ័យតាមការគ្រោងទុក" ។

ក្នុងសន្ទរកថាបិទរបស់**លោក បេនចាមីន ហាកឃីន** មន្ត្រីបច្ចេកទេសសម្រាប់កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍បាន លើកឡើងថា "អង្គការអន្តរជាតិខាងការងារស្វាគន៍យ៉ាងកក់ក្តៅដល់ការតាំងចិត្តដែលធ្វើឡើងដោយដៃគូសហការក្នុងការ ពង្រីកវិសាលភាពនៃការគាំពារដល់ពលករទេសន្តរប្រវេសន៍កម្ពុជាក្នុងវិស័យនេសាទ និងការកែច្នៃអាហារសមុទ្រ។ យើងទទួល ស្គាល់ថាការងារក្នុងវិស័យនេះមានសារៈសំខាន់សម្រាប់ពលករទេសន្តរប្រវេសន៍ ព្រោះដោយយោងតាមបទពិសោធន៍កន្លងមក ដែលមានការរំលោភសិទ្ធិធ្ងន់ធ្ងរក្នុងកំឡុងពេលជ្រើសរើស និងពេលបំពេញការងារ។ យើងពិតជាមានសេចក្តីសោមនស្សរីករាយ

ចំពោះការសម្រេចបាននូវកិច្ចព្រមព្រៀងលើផែនការសកម្មភាពការងារដ៏ល្អនេះ ដែលនឹងឆ្លើយតបទៅនិងតម្រូវការនៃការការពារពលករទេសន្តរប្រវេសន៍″ ។

ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលអាក្រក់ដល់ជីវិតរស់នៅនៃពលករទេសន្តរប្រវេសន៍កម្ពុជា ដែលក្នុងនោះមានអ្នកធ្វើមាតុភូមិនិវត្តន៍ជាច្រើននាក់ ភាគច្រើននៃពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ គឺបណ្ដាលមកពីការបាត់បង់ការងារនិងប្រាក់ចំណូលនៅប្រទេសគោលដៅសំខាន់ៗ ដែលនាំឱ្យមានការធ្លាក់ចុះនៃការផ្ញើប្រាក់មកស្រុកកំណើតវិញ។ ការផ្ញើប្រាក់ត្រឡប់មកផ្ទះនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រួសារនៃជនទេសន្តរប្រវេសន៍ ជាពិសេសស្ត្រីដែលរស់នៅតាមជនបទដាច់ស្រយ៉ាល។

គម្រោងកម្មវិធីសិទ្ធិពលករអាស៊ីអាគ្នេយ៍បានចាប់ផ្ដើមឆ្លើយតបចំពោះតម្រូវការចាំបាច់របស់ពលករទេសន្តរប្រវេសន៍តាមរយៈការតាមដានពីឥទ្ធិពលនៃការរាតត្បាតជំងឺកូវីដ-១៩ចំពោះពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើការនៅប្រទេសថៃ ជាពិសេសពលករដែលធ្វើការក្នុងវិស័យ នេសាទ និងកែច្នៃអាហារសមុទ្រ។ កម្មវិធីបានផ្ដល់ជំនួយសង្គ្រោះបន្ទាន់ដល់ពលករទេសន្តរប្រវេសន៍ប្រមាណ២៣០០នាក់ក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩កន្លងទៅនេះ ហើយពេលនេះកម្មវិធីយើងកំពុងពិភាក្សាជាមួយអង្គការក្នុងស្រុកក្នុងប្រទេសថៃដើម្បីផ្ដល់ជំនួយបន្ថែមក្នុងការជួយដោះស្រាយចំពោះខាតបង់ជីវភាពរស់នៅ និងដោះស្រាយការរំលោភសិទ្ធិការងារដែលប្រឈមដោយពលករទេសន្តរប្រវេសន៍។ ជាងនេះទៀតកម្មវិធីក៏មានផែនការផ្ដល់ជំនួយបន្ថែមដល់ពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍តាមរយៈមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដើម្បីធ្វើឱ្យប្រាកដថាពួកគេបានវិលត្រឡប់ដល់ផ្ទះដោយសុវត្ថិភាព និងអាចបន្តរកឱកាសធ្វើការចិញ្ចឹមជីវិតជាថ្មី។

គម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ គឺជាជាគំនិតផ្ដួចផ្ដើមចេញពីពហុប្រទេសដែលមានរយៈពេលច្រើនឆ្នាំរបស់សហភាពអឺរ៉ុប (EU) និងអង្គការសហប្រជាជាតិ ដែលត្រូវបានអនុវត្តដោយអង្គការអន្តរជាតិខាងការងារ (ILO) ដោយសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។

គម្រោងកម្មវិធីផ្ដល់ជូននូវជំនួយ ការគាំទ្រ និងបច្ចេកទេស ក្នុងគោលបំណងលើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ និងមានសុវត្ថិភាពក្នុងចំណោមបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។ គម្រោងនឹងជួយដោះស្រាយនូវរបៀបនៃការធ្វើការងារនៅក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ ព្រមទាំងជួយដោះស្រាយ នូវបញ្ហាប្រឈម និងហានិភ័យនានាដែលមាននៅក្នុងប្រព័ន្ធទេសន្តរប្រវេសន៍ដែលអាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់ជនទេសន្តរប្រវេសន៍ រួមមានឱនភាពផ្នែកការងារសមរម្យ ការរំលោភបំពាន និងការជួញដូរកម្លាំងពលកម្ម។

ព័ត៌មានអំពីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍អាចរកឃើញតាមរយៈតំណរភ្ជាប់ខាងក្រោម
www.shiptoshorerights.org